ដីកាការពារបណ្តោះអាសន្នលើករណីរំលោភផ្លូវភេទដោយបំពាន និង ដីកាជូនដំណឹងនៃសវនាការ

នេះគឺជាដីកាការពារ**បណ្តោះអាសន្នពិតប្រាកដ**លើករណីរំលោភផ្លូវភេទដោយបំពាន ដែលចៅក្រមចុះហត្ថលេខា ។ ដីកានេះនឹងត្រូវទុកនៅក្នុងសំណុំរឿងតុលាការ ។
អ្នកនឹងត្រូវការមានសំណៅចម្លងមានការបញ្ជាក់ត្រឹមត្រូវរបស់ដីកានេះពីស្មៀន ដើម្បីឲ្យ អ្នកអាចបង្ហាញវាទៅក្រុមនគបាលបាន ។ អ្នកមិនចាំបាច់បង់ប្រាក់សំរាប់សុំសំណៅចម្លងរបស់ដីការនេះទេ ។

ចូរសរសេរឲ្យច្បាស់!

ចូរបំពេញឈ្មោះនៃភាគីដើមបណ្តឹង ។

- បើអ្នកជាជនដែលត្រូវបានការពារ, ចូរបំពេញឈ្មោះរបស់អ្នក ។
- បើជនដែលត្រូវបានការពារជាអនីតិជន, នីតិជនទន់ខ្សោយ ឬនីតិជនផ្សេងទៀតដែល, ដោយព្រោះអាយុ, ពិការ ភាព, សុខភាព ឬភាពគ្មានសិទ្ធិ, មិនអាចដាក់បណ្តឹងទាមទារ(នីតិជនផ្សេង)បាន, ចូរបំពេញឈ្មោះរបស់ជននោះ ។
- ចូរចុះខែថ្ងៃឆ្នាំកំណើតរបស់ភាគីដើមបណ្តឹងនៅត្រង់កន្លែងដែលនិយាយថា"ខែថ្ងៃឆ្នាំកំណើត"។

ចូរបំពេញឈ្មោះរបស់ភាគីចុងបណ្តឹងនិងខែថ្ងៃឆ្នាំកំណើត ។ បើអ្នកមិនដឹងខែថ្ងៃឆ្នាំកំណើតទេ, ចូរដាក់អាយុរបស់ភាគីចុងបណ្តឹង ។

[ចៅក្រមនឹងបំពេញបញ្ចប់ត្រប់ទាំងទម្រង់លិខិតដែលនៅសេសសល់ទាំងប៉ុន្មាន ។]
បើភាគីដើមបណ្តឹងបានរៀបចំដីកាសំរាប់ការចុះហត្ថលេខារបស់មន្ត្រីតុលាការ, ចូរធ្វើតាមការណែនាំទាំងនេះ ៖

> វគ្គ 1, ***ចូរគូសបញ្ជាក់តែក្នុងប្រអប់មួយ*** ដែលពណ៌នាអំពីភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងរបស់អ្នក ៖ អាយុពី 16 ឆ្នាំឡើងទៅ, អនីតិជនក្រោមអាយុ 16 ឆ្នាំ ឬនីតិជនទន់ខ្សោយ ឬនីតិជនផ្សេងទៀត ។
>
> វគ្គ 2, បើភាគីចុងបណ្តឹងមានអាយុក្រោម 16 ឆ្នាំ, ចូរគូសបញ្ជាក់ក្នុងប្រអប់ដែលនៅខាងដើមនៃវគ្គនេះ ។ តុលការនឹងត្រូវតែងតាំងអ្នកអាព្យាបាលបាលិតម្នាក់សំរាប់ភាគីចុងបណ្តឹង មុននឹងដីកាពេញលេញមួយអាចនឹងត្រូវដាក់ចេញ ។
>
> សំរាប់អនុក្រឹត្យហាមឃាត់, ចូរគូសក្នុងប្រអប់ផ្ទួចគ្នានឹងប្រអប់ដែលអ្នកបានគូសនៅក្នុង បណ្តឹងទាមទារ ។
>
> ចំណាំ៖ សំរាប់កម្មវត្ថុទីពីរនិងទីបី, អ្នកអាចនឹងចុះអាសយដ្ឋានរស់នៅរបស់ភាគីដើមបណ្តឹង ។ ភាគីដើមបណ្តឹងមានសិទ្ធិរក្សាអាសយដ្ឋានរស់នៅរបស់គេជាលាក់ការសម្ងាត់) ។ អ្នកមិនត្រូវ បានតម្រូវឲ្យចុះអាសយដ្ឋានរស់នៅរបស់ភាគីដើមបណ្តឹងទេ ប្រសិនបើការបញ្ចេញអាសយដ្ឋានអាចនឹង នាំឲ្យភាគីដើមបណ្តឹងឬក្រុមគ្រួសាររបស់ភាគីដើមបណ្តឹង ជួបប្រទះនូវការ បំពារបំពាន ឬការុកគួនពីសំណាក់ភាគី ចុងបណ្តឹងនោះ

។ តែទោះជាយ៉ាងណាក៏ដោយ, ការអនុវត្តន៍ ច្បាប់របស់ដីកាអាចនឹងមានភាពងាយស្រួល ប្រសិនបើមានអាសយដ្ឋានណាមួយត្រូវបានដាក់បញ្ចូល ។ បើអ្នកសម្រេចចិត្តដាក់បញ្ចូលអាសយដ្ឋានណាមួយ, សូមចុះអាសយដ្ឋាននោះ ឲ្យបានពេញលេញ គឺរួមបញ្ចូលទាំងឈ្មោះទីក្រុងផង ។

ការបញ្ជូលទិន្នន័យអាជ្ញាធរមានសមត្ថកិច្ច

ដីកានឹងនឹងត្រូវបញ្ជូលទៅក្នុងបញ្ជីទិន្នន័យទូទៅទាំងរដ្ឋ ដែលជាទិន្នន័យបានប្រើប្រាស់ដោយអាជ្ញាធរមាន សមត្ថកិច្ច ដើម្បីឲ្យភ្នាក់ងារមានសមត្ថកិច្ចគ្រប់គ្នាដឹងអំពីរឿងនេះ។ ចូរចុះឈ្មោះទីភ្នាក់ងារដែលមានដែន សមត្ថកិច្ចនៅតាមតំបន់ដែលអ្នករស់នៅ ។

- បើអាសយដ្ឋានស្ថិតនៅក្នុងក្រវាត់ដែនក្រុង, ចូរចុះឈ្មោះនគបាលក្រុង ។
- បើអាសយដ្ឋានស្ថិតនៅក្រៅក្រវាត់ដែនក្រុង, ចូរចុះឈ្មោះអាជ្ញាធរខេត្ត ។

ការប្រគល់ដីកាដោយផ្ទាល់

ដីកានេះត្រូវតែបានប្រគល់ជូនដោយផ្ទាល់ដល់ភាគីចុងបណ្តឹង ប្រយោជន៍ឲ្យភាគីចុងបណ្តឹងដឹងថា តើមានអនុក្រឹត្យដាក់កំហិតអ្វីខ្លះត្រូវបានអនុវត្ត, ហើយថា ពេលណានិងកន្លែងណាដែលសវនាការនឹងត្រូវបើកឡើង ។ អ្នកអាចនឹងជ្រើសរើស ៖

- ទីភ្នាក់ងារមានសមត្ថកិច្ចមួយ; (ចំណាំ៖ អ្នកអាចនឹងត្រូវបង់ថ្លៃសេវាកម្ម ។)
- ភ្នាក់ងារឯកទេសស៊ីឈ្នួលប្រគល់ដីការបញ្ជា;
- ជនណាម្នាក់ដែលមានអយុពី 18 ឆ្នាំឡើងទៅ, ដែលមិនមែនជាគ្ងភាគីម្នាក់ក្នុងរឿងក្តីនេះ ។

អ្នកនឹងត្រូវការផ្តល់អាសយដ្ឋានមួយ ដែលជាកន្លែងគេអាចរកភាគីចុងបណ្តឹងឃើញសំរាប់ការប្រគល់ដីកានេះ ។

ចូរគ្ងសបញ្ជាក់ក្នុងប្រអប់ដែលត្រឹមត្រូវ ហើយបំពេញឈ្មោះទីភ្នាក់ងារអាជ្ញាធរមានសមត្ថកិច្ច ដែលអាចនឹងរកឃើញ **ទីកន្លែងដែលភាគីចុងបណ្តឹងរស់នៅ** ដើម្បីឲ្យនគបាលអាចប្រគល់បណ្តឹងនិងដីកានេះដល់ភាគីចុងបណ្តឹង ។

បើភាគីចុងបណ្តឹងមានអាយុក្រោមអាយុ18 ឆ្នាំ, ចូរគ្ងសបញ្ជាក់ក្នុងប្រអប់ដែលត្រឹមត្រូវ ហើយបំពេញឈ្មោះទីភ្នាក់ងារអាជ្ញាធរមានសមត្ថកិច្ច ដែលអាចនឹងរកឃើញ**ទីកន្លែងដែលឪពុក-ម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ភាគីចុងបណ្តឹងរស់នៅ** ដើម្បីឲ្យនគបាលអាចប្រគល់បណ្តឹងនិងដីកានេះដល់ឪពុក-ម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ភាគីចុងបណ្តឹង ។

បើអ្នកកំពុងធ្វើការចាត់ចែងជាឯកជនសំរាប់ប្រគល់បណ្តឹងនិងដីកានេះដោយផ្ទាល់, ចូរគ្ងសបញ្ជាក់ក្នុងប្រអប់នោះ ។

បើភាគីចុងបណ្ឹងបង្ហាញខ្លួនក្នុងសវនាការសំរាប់ភាគីមួយចំហៀង ហើយតុលាការបានប្រគល់សំណៅចម្លងនៃបណ្តឹងនិងដីកានេះដល់ភាគីចុងបណ្តឹង, ចូរគ្ងសបញ្ជាក់ក្នុងប្រអប់"ការប្រគល់ដីកា" ដែលនៅចុងក្រោយបង្អស់។ គ្មានការតម្រូវឲ្យប្រគល់ដីកាបន្ថែមទេ។

សវនាការលើកក្រោយ

ព័ត៌មាននៅលើទំព័រទី 3 ណែនាំភាគីចុងបណ្តឹងឲ្យបង្ហាញខ្លួនក្នុងសវនាការលើកក្រោយ ។ ចៅក្រមឬស្នៀនតុលាការនឹងចុះជាលាយលក្សអក្សរនូវកាលបរិច្ឆេទនៃសវនាការលើកក្រោយ, ពេលវេលានិងទីកន្លែង, នៅខាងក្រោមចំណងជើងលើទំព័រទីមួយ ។ ភាគីដើមបណ្តឹងក៏ត្រូវតែចូលរួមក្នុងសវនាការនេះផងដែរ ។

- បើភាគីដើមបណ្តឹងមិនមកស្តាប់សវនាការនេះទេ, បណ្តឹងនឹងត្រូវលើកចោល ហើយភាគីដើមបណ្តឹងនឹងមិនត្រូវបានការពារដោយដីកាណាមួយឡើយ ។
- បើភាគីចុងបណ្តឹងមិនមកស្តាប់សវនាការនេះទេ, តុលាការអាចនឹងនៅតែធ្វើអនុប្បទានដីកាការពារ ដើម្បីការពារភាគីដើមបណ្តឹង, ដរាបណាភាគីចុងបណ្តឹងត្រូវបានគេប្រគល់ជូនដោយផ្ទាល់ នូវបណ្តឹងនិងដីការបណ្តោះអាសន្ន សំរាប់ការពារនិងការជូនដំណឹងរបស់សវនាការនេះ ។

ចូរចុះហត្ថលេខានៅផ្នែកខាងក្រោមនៃទម្រង់លិខិតនេះ ។

- បើអ្នកកំពុងប្តឹងក្នុងនាមខ្លួនអ្នកផ្ទាល់, ចូរចុះហត្ថលេខានៅខាងលើបន្ទាត់សំរាប់ "ហត្ថលេខានៃភាគីដើមបណ្តឹង" ។
- បើអ្នកកំពុងប្តឹងក្នុងនាមរបស់អនីតិជន, នីតិជនទន់ខ្សោយ ឬនីតិជនណាដទៃទៀត, ចូរចុះហត្ថលេខានៅខាងលើបន្ទាត់សំរាប់ "ហត្ថលេខានៃជនដាក់ប្តឹងក្នុងនាមភាគីដើមបណ្តឹង" ។

ខាងក្រោមនេះគឺជាគំរូនៃដីកាការពារបណ្តោះអាសន្នលើករណីរំលោភផ្លូវភេទដោយបំពាន និង ដីកាជូនដំណឹងនៃសវនាការ ៖

ចំណាំ៖ អ្នកត្រូវតែបំពេញទម្រង់លិខិតនេះជាភាសាអង់គ្លេស

Court of Washington **(តុលាការនៃរដ្ឋវ៉ាស៊ីនតោន)** **For (សំរាប់)**	**No. (លេខ)**
Petitioner (Protected Person) ____ DOB ____ ភាគីដើមបណ្តឹង(ជនត្រូវបានការពារ) ខែ ថ្ងៃ ឆ្នាំ កំណើត vs. ទល់នឹង Respondent (Restrained Person) ____ DOB ____ ភាគីចុងបណ្តឹង(ជនត្រូវបានហាមឃាត់) ខែ ថ្ងៃ ឆ្នាំ កំណើត	**Temporary Sexual Assault Protection Order and Notice of Hearing** **(TMORSXP) (JIS Order Code: TSX)** ដីកាការពារបណ្តោះអាសន្នលើករណីរំលោភផ្លូវភេទដោយបំពាន និងដីកាជូនដំណឹងនៃសវនាការ ☐ **Clerk's Action Required** **តម្រូវឲ្យមានកិច្ចការរបស់ស្មៀន** **Next Hearing Date/Time:** កាលបរិច្ឆេទ/ពេលវេលានៃសវនាការលើកក្រោយ ៖ ____ **At: (**នៅ ៖**)**____

1. ***The Court Finds*** by a preponderance of the evidence that petitioner is a victim of nonconsensual sexual conduct or nonconsensual sexual penetration as defined in Laws of 2006, ch. 138, § 2 by the respondent, and:
   តុលាការរកឃើញ ដោយឧត្តមានុភាពនៃភស្តុតាងថា ាគីដើមបណ្តឹងគឺជាជនរងគ្រោះនៃករណីប្រព្រឹត្តិផ្លូវភេទដោយគ្មានការព្រមព្រៀង ឬករណីបានសម្រេចផ្លូវភេទដោយគ្មានការព្រមព្រៀង ្ចដែលបានកំណត់ដោយច្បាស់លាស់នៅក្នុងច្បាប់នៃ 2006, ch. 138, § 2 ដោយភាគីចុងបណ្តឹង, ហើយ ៖

   ☐ Petitioner is 16 years of age or older.
   ភាគីដើមបណ្តឹងមានអាយុ 16 ឆ្នាំឬចាស់ជាង ។

   ☐ Petitioner is a minor child, age _____, on whose behalf the petition is brought. Petitioner's parent(s) or legal guardian(s) are bringing this action and are appointed as the petitioner's guardian ad litem for this proceeding.

ភាគីដើមបណ្តឹងជាក្មេងអនីតិជនម្នាក់, អាយុ_____, ដោយតាងឲ្យនាមរបស់គេនេះហើយ ទើបបណ្តឹងនេះ ត្រូវបានប្តឹងមក ។ ឪពុក-ម្តាយឬអ្នកអាណាព្យាបាលស្របច្បាប់របស់ភាគីដើមបណ្តឹងកំពុងតែដាក់បណ្តឹងនេះ ហើយត្រូវ បានតែងតាំងឲ្យធ្វើជាអាណាព្យាបាលចាលិតរបស់ភាគីដើមបណ្តឹងសំរាប់ដំណើរការនីតិវិធីក្តីនេះ ។

☐ Petitioner is a vulnerable adult as defined in RCW 74.34.020 or 74.34.021; or other adult who, because of age, disability, health, or inaccessibility, cannot file the petition.
ភាគីដើមបណ្តឹងជានីតិជនទន់ខ្សោយម្នាក់ ដូចដែលបានកំណត់ដោយច្បាស់លាស់នៅក្នុង RCW 74.34.020 ឬ 74.34.021; ឬនីតិជនណាដទៃទៀតដែល, ដោយព្រោះអាយុ, ពិការភាព, សុខភាព, ឬភាពគ្មានសិទ្ធិ, មិនអាចដាក់ បណ្តឹងនេះបាន ។

2. ☐ Respondent is under 16 years of age. The court will determine at the next hearing whether respondent's parent or guardian or an attorney should be appointed as guardian ad litem to represent the respondent in this proceeding.
ភាគីចុងបណ្តឹងមានអាយុក្រោម 16 ឆ្នាំ ។ តុលាការនឹងសម្រេចនៅពេលបើកសវនាការលើកក្រោយ ថាតើឪពុ-ម្តាយ ឬអ្នកអាណាព្យាបាល ឬមេធាវីរបស់ភាគីចុងបណ្តឹងគួរត្រូវតែតាំងឲ្យធ្វើជាអាណាព្យាបាលចាលិត ដើម្បីតំណាងឲ្យ ភាគីចុងបណ្តឹងនៅក្នុងដំណើរការនីតិវិធីក្តីនេះឬយ៉ាងណា ។

The Court Further Finds that there is good cause to grant each remedy, regardless of prior service of process or of notice upon the respondent, because the harm which each remedy is intended to prevent would be likely to occur if the respondent were given any prior notice, or greater notice than was actually given, of the petitioner's efforts to obtain judicial relief. ***It Is Therefore Ordered*:**

តុលាការរកឃើញទៀតថា មានមូលហេតុត្រឹមត្រូវដើម្បីធ្វើអនុប្បទានមធ្យោបាយផ្លូវច្បាប់និមួយៗ, ដោយមិនគិតដល់ការ ចេញដីកាបញ្ជាឬដីកាជូនដំណឹងចំពោះភាគីចុងបណ្តឹងពីដំបូងៗមកទេ, ពីព្រោះថាគ្រោះថ្នាក់ ដែលមធ្យោបាយផ្លូវច្បាប់ និមួយៗត្រូវបានដាក់ចេញឲ្យការពារ អាចទំនងនឹងកើតឡើង បើសិនជាភាគីចុងបណ្តឹងត្រូវបានគេឲ្យដីកាជូនដឹងតំបូងណា មួយឬដីការឹតបន្តឹងពីបូងណាមួយឲ្យបានខ្លាំងក្លាជាងដីកាដែលបានប្រគល់ឲ្យពិតប្រាកដនោះ, ដល់កិច្ចខិតខំប្រឹងប្រែងរបស់ ភាគីដើមបណ្តឹង ដើម្បីទទួលការស្តារឡើងវិញតាមផ្លូវតុលាការ ។ ***អាស្រ័យហេតុនេះ តុលាការចេញបញ្ជា៖***

☐ 1. Respondent is ***Restrained*** from having any contact with the petitioner, including but not limited to telephone calls, mail, e-mail, fax and written notes, directly, indirectly, or through third parties regardless of whether those third parties know of the order.
ភាគីចុងបណ្តឹង***ត្រូវបានហាមឃាត់*** ពីការទាក់ទងណាមួយជាមួយភាគីដើមបណ្តឹង, រួមមានទាំង តែមិនកម្រិតចំពោះ ការហៅតាមទូរស័ព្ទ, ផ្ញើសំបុត្រ, ផ្ញើអ៊ីម៉ែល, ផ្ញើទូរសារ និងកំណត់ជាលាយលក្សអក្សរនានា, ដោយត្រង់ផ្ទាល់, ដោយមិនត្រង់ផ្ទាល់ ឬតាមរយៈអ្នកទីបីណា។ ដោយពុំគិតថាភាគីទីបីទាំងឡាយនោះដឹងឬមិនដឹងពីដីកានេះទេ ។

☐ 2. Respondent is ***Excluded*** from the following places:
ភាគីចុងបណ្តឹងត្រូវបានបដិសេធចេញពីទីកន្លែងដូចតទៅ៖

☐ Petitioner's residence គេហដ្ឋានរបស់ភាគីដើមបណ្តឹង

☐ Petitioner's workplace កន្លែងធើការរបស់ភាគីដើមបណ្តឹង

☐ Petitioner's school សាលារៀនរបស់ភាគីដើមបណ្តឹង

☐ Petitioner's day care មណ្ឌលមើលក្មេងពេលថ្ងៃរបស់ភាគីដើមបណ្តឹង

☐ Other: ផ្សេងៗ៖

☐ 3. Respondent is ***Prohibited*** from knowingly coming within, or knowingly remaining within _____ (distance) of:
ភាគីចុងបណ្តឹងត្រូវបានដាក់បំរាមពីការចូលមកក្នុងបរិវេណដោយចេតនា, ការស្ថិតក្នុងបរិវេណដោយចេតនា _____ (ចម្ងាយ)ពី៖

☐ Petitioner's residence គេហដ្ឋានរបស់ភាគីដើមបណ្តឹង

☐ Petitioner's workplace កន្លែងធើការរបស់ភាគីដើមបណ្តឹង

☐ Petitioner's school សាលារៀនរបស់ភាគីដើមបណ្តឹង

☐ Petitioner's day care មណ្ឌលមើលក្មេងពេលថ្ងៃរបស់ភាគីដើមបណ្តឹង

☐ Other: ផ្សេងៗ៖

☐ 4. **Other**: **(ផ្សេងៗ៖)**

The respondent may petition the court to reopen the order if the respondent did not receive actual prior notice of the hearing and if the respondent alleges that he or she had a meritorious defense to the order or that the order or its remedy is not authorized by Laws of 2006, ch. 138.

ភាគីចុងបណ្តឹងអាចនឹងប្តឹងឲ្យតុលាការបើកដីកានេះឡើងវិញ បើភាគីចុងបណ្តឹងមិនបានទទួលដីការជូនដំណឹងនៃសវនាការពិតប្រាកដទេនោះ ហើយបើភាគីចុងបណ្តឹងអះអាងថា គេសមនឹងទទួលបានការការពារខ្លួនមួយចំពោះដីកា ឬថា ដីកាឬមធ្យោបាយផ្លូវច្បាប់របស់ដីកាមិនត្រូវបានអនុញ្ញាតឲ្យដោយច្បាប់ 2006, ch. 138 ។

It is further ordered that the clerk of the court shall forward a copy of this order on or before the next judicial day to _____ ☐ County Sheriff's Office ☐ Police Department ***Where Petitioner Lives*** which shall enter it in a computer-based criminal intelligence system available in this state used by law enforcement to list outstanding warrants.

ករណីនេះត្រូវបានដាក់បញ្ជាថែមទៀតថា ស្មៀនរបស់តុលាការនឹងបញ្ជូនសំណៅចម្លងរបស់ដីកានេះមួយច្បាប់នៅចំ ឬមុនថ្ងៃបើកសេចក្តីវិនិច្ឆ័យលើកក្រោយទៅ _____ ☐ ការិយាល័យតម្លួតខោនធី ☐ ក្រសួងនគបាលនៅ ***កន្លែងភាគីដើមបណ្តឹងរស់នៅ*** ដែលនឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធស៊ើបការឧក្រិដ្ឋកម្មមូលដ្ឋានកុំព្យូទ័រដែលមានក្នុងរដ្ឋនេះ សំរាប់ប្រើប្រាស់ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះបញ្ជីអនុវត្តន៍ដីកាចាប់ខ្លួន ។

Service (ការប្រគល់ដីកាដោយផ្ទាល់)

☐ The clerk of the court shall also forward a copy of the petition and order on or before the next judicial day to _____ ☐ County Sheriff's Office ☐ Police Department ***Where Respondent Lives*** which shall personally serve the respondent with a copy of the petition and order and shall promptly complete and return to this court proof of service.
ស្មៀនរបស់តុលាការក៏នឹងបញ្ជូនសំណៅចម្លងនៃបណ្តឹងនិងដីកានេះមួយច្បាប់ នៅចំឬមុនថ្ងៃបើកសេចក្តីវិនិច្ឆ័យលើក ក្រោយ ទៅ _____ ☐ ការិយាល័យតម្រួតខោនធី

☐ ក្រសួងនគបាលនៅ ***កន្លែងភាគីដើមបណ្តឹងរស់នៅ*** ដែលនឹងត្រូវប្រគល់ជូនដោយផ្ទាល់ទៅភាគីចុងបណ្តឹងនូវសំណៅ ចម្លងនៃបណ្តឹងនិងដីកានេះផងដែរ ហើយគេនឹងបំពេញរបាយការណ៍ រួចបញ្ជូនត្រឡប់ទៅកាន់តុលាការនេះវិញយ៉ាង ឆាប់រហ័ស ដើម្បីទុកជាភស្តុតាងនៃការប្រគល់ដីកានេះ ។

☐ The clerk of the court shall also forward a copy of the petition and order on or before the next judicial day to _____ ☐ County Sheriff's Office ☐ Police Department for service of the petition and order upon _____ _____(Respondent's Parent(s) or Legal Guardian(s)) at: _____ _____and shall promptly complete and return to this court a Return of Service.
ស្មៀនរបស់តុលាការក៏នឹងបញ្ជូនសំណៅចម្លងនៃបណ្តឹងនិងដីកាមួយច្បាប់ នៅចំឬមុនថ្ងៃបើកសេចក្តីវិនិច្ឆ័យលើកក្រោយ ទៅ _____ ☐ ការិយាល័យតម្រួតខោនធី ☐ ក្រសួងនគបាលសំរាប់ត្រគល់ជូនបណ្តឹងនិងដីកាទៅ _____ _____(ឪពុកម្តាយឬអ្នកអាណាព្យាបាលស្របច្បាប់របស់ភាគីចុងបណ្តឹង) នៅ៖_____ _____ហើយគេ នឹងបំពេញរបាយការណ៍ប្រគល់ដីកា រួចបញ្ជូនត្រឡប់ទៅកាន់តុលាការនេះវិញយ៉ាងឆាប់រហ័ស ។

☐ Petitioner has made private arrangements for service of the petition and order. (A Return of Service shall be filed with the court at or before the next hearing.)
ភាគីដើមបណ្តឹងបានធ្វើការចាត់ចែងជាឯកជនសំរាប់ការប្រគល់បណ្តឹងនិងដីកានេះ ។ (ភាគីដើម បណ្តឹងនឹង ត្រូវបំពេញរបាយការណ៍ប្រគល់ដីកា ប្តឹងទៅតុលាការ ឲ្យបានទាន់ឬមុនថ្ងៃបើកសវនាការលើកក្រោយ ។)

☐ Respondent appeared and was served a copy of the petition and order by the court; further service is not required.
ភាគីចុងបណ្តឹងបានបង្ហាញខ្លួន ហើយតុលាការបានត្រគល់សំណៅចម្លងនៃបណ្តឹងនិងដីកាមួយច្បាប់; មិនតម្រូវឲ្យមាន ការប្រគល់ដីកាបន្ថែមណាទៀតទេ ។

The respondent is directed to appear and show cause why this temporary sexual assault protection order should not be made effective for up to two years and why the court should not order the relief requested by the petitioner. If respondent is under 16 years of age then his or her parent(s) or legal guardian(s) shall also appear.

ភាគីចុងបណ្តឹងត្រូវបានបង្គាប់ឲ្យបង្ហាញខ្លួន ហើយបញ្ជាក់មូលហេតុថាហេតុអ្វីបានជាដីកាការពារបណ្តោះអាសន្ន លើករណីរំលោភផ្លូវភេទដោយបំពានេះ មិនគួរត្រូវដាក់ចេញជាធរមានសំរាប់រយៈពេលពីរឆ្នាំទៅមុខ

ហើយហេតុអ្វីបានជាតុលាការមិនគួរចេញដីកាបញ្ជាឲ្យមានការស្តារឡើងវិញ ដូចដែលបានស្នើសុំដោយ ភាគីដើមបណ្តឹង ។ បើភាគីចុងបណ្តឹងមានអាយុក្រោម 16 ឆ្នាំ នោះឪពុក-ម្តាយឬអ្នកអាណាព្យាបាលស្រប ច្បាប់របស់គេក៏នឹងត្រូវបង្ហាញខ្ជូនផងដែរ ។

Failure to Appear at the Hearing May Result in the Court Granting All of the Relief Requested in the Petition.

ការខកខានមិនបានបង្ហាញខ្ជូនក្នុងសវនាការអាចនឹងបណ្តាលឲ្យតុលាការធ្វើអនុប្បទានដល់គ្រប់ទាំងការស្តារឡើង វិញ ដែលត្រូវបានដាក់ស្នើសុំក្នុងបណ្តឹង ។

***Warnings To The Respondent*: A knowing violation of this sexual assault protection order is a criminal offense under chapter 26.50 RCW and *will subject a violator to arrest*. You can be arrested even if any person protected by the order invites or allows you to violate the order's prohibitions. You have the sole responsibility to avoid or refrain from violating the order's provisions. Only the court can change the order.**

ការព្រមានចំពោះភាគីចុងបណ្តឹង៖ ការបង្កបទល្មើសដោយចេតនាលើដីកាការពារលើ ករណីរំលោភផ្ទូវភេទ ដោយ បំពាន នេះគឺជាបទល្មើសឧក្រិដ្ឋមួយក្រោមច្បាប់ **Chapter 26.50 RCW** ហើយ *ជនបង្កបទល្មើសនិងត្រូវចាប់ខ្ជូន* ។ អ្នកអាចត្រូវចាប់ខ្ជូន បើទោះជាមានភាគីដែលត្រូវបាន ការ ពារណាម្នាក់ បានអញ្ជើញអ្នក ឬអនុញ្ញាតឲ្យអ្នកប្រព្រឹត្តល្មើសនឹងបំរាមនានា របស់ដីកាក៏ដោយ ក្តី ។ អ្នកមានបន្ទុក ទទួលខុសត្រូវពេញទី ដើម្បីខំជៀសវាង ឬទប់ទលនឹងការបង្កបទល្មើសទាស់នឹងអនុក្រឹត្យ របស់ដីកា ។ មានតែតុលាការមួយបណ្ណោះទេដែលអាចកែប្រែដីកាបាន ។

This Temporary Sexual Assault Protection Order is Effective Until the Next Hearing Date Shown on Page One.

ដីកាការពារបណ្តោះអាសន្នលើករណីរំលោភផ្ទូវភេទដោយបំពាននេះត្រូវបានដាក់ចូលជាធរមានរហូតដល់ កាលបរិច្ឆេទនៃ សវនាការលើកក្រោយ ដូចបានបញ្ជាក់ជូននៅលើទំព័រទីមួយ ។

Dated:_____ at _____ a.m./p.m. _____

កាលបរិច្ឆេទ៖ នៅ ព្រឹក/រសៀល **Judge/Commissioner**

ចៅក្រម/ស្នងការ

Presented by:

បានបញ្ហាញជូនដោយ៖

_____

Signature of Petitioner

ហត្ថលេខានៃភាគីដើមបណ្តឹង

_____

Signature of Person Filing on Behalf of the Petitioner

ហត្ថលេខានៃជនដែលជួយប្តឹងក្នុងនាមនៃភាគីដើមបណ្តឹង

A Law Enforcement Information Sheet (LEIS) must be completed.

ត្រូវតែបំពេញក្រដាសព័ត៌មាននៃអាជ្ញាធរមានសមត្ថកិច្ច (LEIS) ។